# ពពួកក្រុមសិស្សដែលនឹងសិក្សាចប់សាលាវិទ្យាល័យឆ្នាំ 2006
# សេចក្តីតម្រូវពីសាលា UC, CSU និង NCAA

## ជំពូកមុខវិជ្ជាដែលតំរូវឲ្យសិស្សបានរៀនឲ្យហើយសំរាប់សុំចូលសាលាសាកលវិទ្យាល័យ University of California និង California State University

ថ្នាក់តាមលេខរៀងជាលំដាប់លំដោយនៅសាលាវិទ្យាល័យដែលមានរាយខាងក្រោមនេះគឺបានតំរូវឲ្យសិស្សសាលាវិទ្យាល័យបានរៀនហើយសម្រាប់សុំចូលទៅរៀននៅសាលាសាកលវិទ្យាល័យ University of California ។ វាក៏បង្ហាញដែរនូវកំរឹតទាបបំផុតដែលសិស្សបានរៀបបំរុងនៅសាលាវិទ្យាល័យសម្រាប់ការសិក្សានៅសាលាសាកលវិទ្យាល័យ។

សេចក្តីតម្រូវនូវមុខវិជ្ជាជំពូក “a-g” មានសង្ខេបខាងក្រោមនេះ:

**A ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រខាងសង្គម**– ត្រូវការពីរឆ្នាំ ដែលមួយឆ្នាំគឺថ្នាក់ U.S. History ឬកន្លះឆ្នាំថ្នាក់ U.S. History និងកន្លះឆ្នាំទៀតថ្នាក់ civics ឬ American Government; ហើយនិងមួយឆ្នាំនូវថ្នាក់ប្រវត្តិសាស្ត្រពិភពលោក ថ្នាក់វប្បធម៌ និងថ្នាក់ភូមវិទ្យា។

**B អង់គ្លេស**– ត្រូវការបួនឆ្នាំនូវថ្នាក់អង់គ្លេសដែលរៀបបំរុងសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ។ ថ្នាក់ទាំងនោះគឺថ្នាក់រៀនសរសេរ ថ្នាក់អានអក្សរសាស្ត្រតន្តីនិងទំនើប។

**C គណិតសាស្ត្រ**– ត្រូវការបីឆ្នាំនូវថ្នាក់គណិតសាស្ត្រដែលរៀបបំរុងសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ។ ថ្នាក់ទាំងនោះគឺថ្នាក់ពេជគណិតកំរឹតដើមនិងកំរឹតខ្ពស់ ហើយនិងថ្នាក់រេខាគណិតពីរនិងបីឌីម៉ង់ស្យុង។

**D វិទ្យាសាស្ត្រដែលមានការពិសោធន៍**– ត្រូវការ២ឆ្នាំនូវថ្នាក់ពិសោធន៍វិទ្យាសាស្ត្រដែលផ្តល់ការចេះដឹងទៅលើវិស័យជីវសាស្ត្រ(រាងកាយ សរីរវិទ្យា ជលជីវ-សាស្ត្រ ។ល។) គីមី និងរូបវិទ្យា ឬបីឆ្នាំនៃថ្នាក់វិទ្យាសាស្ត្រលាយចូលគ្នា។

**E ភាសាក្រៅពីភាសាអង់គ្លេស**– ពីរឆ្នាំក្នុងភាសាតែមួយដែលផ្សេងពីភាសាអង់គ្លេស។ បីឆ្នាំរឹតតែប្រសើរ។

**F សិល្បៈសម្តែងឬរចនា**– មួយឆ្នាំនៃថ្នាក់ក្នុងវិស័យទាំងបីខាងក្រោមនេះ: រាំ ល្ខោន ឬការរចនាឬគូររូប។

**G ថ្នាក់រើសបានតាមចំណូលចិត្ត**– ថែមពីថ្នាក់ដែលតម្រូវនៅក្នុងមុខវិជ្ជាជំពូក “a-f” ខាងលើនេះ សិស្សក៏តម្រូវឲ្យយកថ្នាក់រៀបបំរុងសម្រាប់ការសិក្សានៅឯសាលាសាកលវិទ្យាល័យឲ្យបាន១ឬ២ឆមាសផងដែរ។ ថ្នាក់ទាំងនោះគឺជាថ្នាក់ដែលអាចរើសបានតាមចំណូលចិត្តដូចជា សិល្បៈសំដែងឬរចនា ប្រវត្តិវិទ្យា វិទ្យាសាស្ត្រសង្គម អង់គ្លេស ចំណោទកំរឹតខ្ពស់ និងភាសាក្រៅពីអង់គ្លេស។

សិស្សត្រូវរៀនឲ្យបានយ៉ាងតិចត្រឹមពិន្ទុ “C” ទើបគេគិតរាប់យក។

## សេចក្តីតម្រូវពីសាលាសម្រាប់កីឡាករ NCAA

### ការតម្រូវចំពោះកីឡាករ

### ការតម្រូវជាលើកដំបូងពីសាលា NCAA

សិស្សណាដែលចង់បន្តកម្មវិធីកីឡាក្រោយពីសិក្សាចប់នៅសាលាវិទ្យាល័យត្រូវតែបំពេញនូវសេចក្តីតម្រូវមួយចំនួន។ អង្គការ National Collegiate Athletic Association (NCAA) គឺជាអង្គការកម្មវិធីកីឡាដែលគ្រប់គ្រងមើលសាលាមហាឬសាកលវិទ្យាល័យប្រមាណជា 800 សាលា។ ការសិក្សាជាបមាណីយគឺមានរួមទាំងសញ្ញាប័ត្រពីសាលាវិត្យាល័យ ពិន្ទុ GPA ពីថ្នាក់ចាំបាច់ដែលតម្រូវឲ្យយកហើយនិងសេចក្តីតម្រូវផ្សេងៗទៀតក្នុងការទទួលឲ្យចូលរៀន។

ពិន្ទុ GPA ពីថ្នាក់ចាំបាច់របស់NCAA គឺគិតដោយប្រើពិន្ទុដែលបានទទួលល្អជាងគេនៅក្នុងមុខវិជ្ជា១៤មុខនៃការសិក្សានៅសាលាវិទ្យាល័យ។ ការតម្រូវក្នុងថ្នាក់ចាំបាច់ទាំងនោះគឺ:

- 4 ឆ្នាំនូវថ្នាក់អង់គ្លេស
- 2 ឆ្នាំនូវថ្នាក់គណិតសាស្ត្រកំរឹតខ្ពស់ ដែលមួយឆ្នាំត្រូវមានថ្នាក់ពេជគណិត
- 2 ឆ្នាំនូវថ្នាក់ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រសង្គម
- 2 ឆ្នាំនូវថ្នាក់វិទ្យាសាស្ត្រ ដែលមួយឆ្នាំត្រូវមានថ្នាក់ពិសោធន៍វិទ្យាសាស្ត្រ
- 1 ឆ្នាំបន្ថែមទៀតនូវថ្នាក់អង់គ្លេស គណិតសាស្ត្រ ឬធម្មវិទ្យារូបវិទ្យា
- 3 ឆ្នាំបន្ថែមនូវថ្នាក់ទាំងឡាយខាងលើនេះឬថ្នាក់ភាសាបរទេស

សូមកត់សម្គាល់ថាថ្នាក់កុមព្យូទ័រត្រូវបានលែងគិតថាជាថ្នាក់ចាំបាច់ទៀតហើយ។

សិស្សណាដែលចង់រៀនឲ្យបានថ្នាក់កំរឹតសាលាមហាឬសាកលវិទ្យាល័យ Division I ឬ Division II ត្រូវរៀនឲ្យបានយ៉ាងតិចត្រឹមពិន្ទុ “C” ចំពោះថ្នាក់ទាំងនោះ។ វាជាភារៈកិច្ចរបស់សិស្សក្នុងការដាក់ពាក្យសុំបន្តកម្មវិធីកីឡានៅដើមឆ្នាំទីបួននៅសាលាវិទ្យាល័យ។ បើមានសំនួរអ្វីមួយសូមទាក់ទងអ្នកផ្តល់ឱវាទភ្ជួយអគ្គនាយក ការិយាល័យ Office of Curriculum, Instruction & Professional Development ឬអង្គការ NCAA តាមលេខ (800) 638-3731 ឬតាមរយៈអ៊ិនធើនែតតាមអាស័យដ្ឋានវេបសាយ http://www.ncaa.org ។